

# ការបំពាក់ បំប៉នវគ្គសិក្សាមូលដ្ឋានគ្រឹះ

សាសនាចក្រនៃ
ព្រះយេស៊ូវគ្រីស្ទ
នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ

លក្ខខណ្ឌប្រើប្រាស់ ( បានធ្វើបច្ចុប្បន្នភាពនៅថ្ងៃទី ០៤-១៣-២០២១ )  កំណត់សម្គាល់ឯកជនភាព ( បានធ្វើបច្ចុប្បន្នភាពនៅថ្ងៃទី ០៤-០៦-២០២១ )
© 2021 by Intellectual Reserve, Inc. All rights reserved.

ការស្វាគមន៍ និងលទ្ធផលសម្រាប់វគ្គសិក្សាមូលដ្ឋានគ្រឹះ



## *សូមស្វាគមន៍*

សូមស្វាគមន៍មកកាន់ការបង្រៀនវគ្គសិក្សាមូលដ្ឋានគ្រឹះថ្នាក់វិទ្យាស្ថាន ! សូមអរគុណចំពោះការព្រមទទួលយកឱកាស ដើម្បីជួយសិស្សរបស់អ្នកឲ្យមានការផ្លាស់ប្រែចិត្តជឿកាន់តែជ្រាលជ្រៅទៅលើព្រះយេស៊ូវគ្រីស្ទ និងដំណឹងល្អរបស់ទ្រង់ដែលបានស្ដារឡើងវិញ ។

## *ពីមុនការបង្រៀន*

ពីមុនការបង្រៀន អ្នកនឹងចង់ ៖

- រំឭក សេចក្តីណែនាំចាប់ផ្តើមឆាប់រហ័ស សម្រាប់ការបង្រៀនវគ្គសិក្សាមូលដ្ឋានគ្រឹះ
- សិក្សាបុព្វកថានៅក្នុង ឯកសារគ្រូបង្រៀន ដោយយកចិត្តទុកដាក់ ។
- រៀបចំពេលវេលាដើម្បីជួបជាមួយអ្នកសម្របសម្រួល ឬនាយកថ្នាក់វិទ្យាស្ថាន ដើម្បីពិភាក្សាអំពីកិច្ចការរបស់អ្នក សិស្ស វគ្គសិក្សា និងសំណួរណាមួយដែលអ្នកមាន ។
- អធិស្ឋានសម្រាប់ការណែនាំដើម្បីជួយសិស្សរបស់អ្នកឲ្យមករកព្រះគ្រីស្ទ និងកាន់តែប្រែក្លាយដូចជាទ្រង់ ។

## *កម្មវត្ថុនៃការបំពាក់បំប៉នបុគ្គលិក*

មានគោលការណ៍ និងជំនាញជាច្រើនដែលសំខាន់សម្រាប់ការបង្រៀនដ៏មានប្រសិទ្ធភាព ។ អ្នកអាចបន្តសិក្សាគោលការណ៍ទាំងឡាយ ហើយអនុវត្តជំនាញដែលបានបង្រៀននៅក្នុងសៀវភៅក្បួនខ្នាតថ្នាក់សិក្ខាសាលា និងថ្នាក់វិទ្យាស្ថាន ។ សម្រាប់គោលបំណងនៃការបំពាក់បំប៉នបុគ្គលិកនេះ នោះយើងនឹងកំណត់ ដាក់ជាគំរូ និងអនុវត្តជំនាញគន្លឹះពីរបី ដែលទាក់ទងនឹងការបង្រៀនវគ្គសិក្សាមូលដ្ឋានគ្រឹះថ្នាក់វិទ្យាស្ថាន ដើម្បីជួយតម្រង់ទិសអ្នកមកកាន់វគ្គសិក្សា និងកម្មវិធីសិក្សានេះ ។ ជំនាញទាំងនេះអាចជួយអ្នកឲ្យផ្តល់បទពិសោធន៍ដ៏ស្អាងឡើង និងប្រែចិត្ត

ជឿងលល់សិស្សទាំងឡាយ កាលអ្នកព្យាយាមជួយពួកគេឲ្យរៀបចំខ្លួន ចូលរួម និងធ្វើសកម្មភាព ដើម្បីជួយពួកគេឲ្យក្លាយដូចជាព្រះអង្គសង្គ្រោះព្រះយេស៊ូវគ្រីស្ទ ។




- **រៀបចំខ្លួន ៖** លើកកម្ពស់ការរៀបចំខ្លួនរបស់សិស្សតាមរយៈការអញ្ជើញ
- **ឲ្យចូលរួម ៖** ឲ្យសិស្សចូលរួមដោយផ្អែកលើការរៀបចំខ្លួនរបស់ពួកគេ
- **ធ្វើសកម្មភាព ៖** សង្កត់ធ្ងន់លើការអនុវត្ត

លើកកម្ពស់ការរៀបចំខ្លួនរបស់សិស្សតាមរយៈការអញ្ជើញ



## *ជំនាញ ៖ លើកកម្ពស់ការរៀបចំខ្លួនរបស់សិស្សតាមរយៈការអញ្ជើញ*

តើអ្នកនឹងលើកកម្ពស់ការរៀបចំខ្លួនរបស់សិស្សអ្នក ដើម្បីកែលម្អបទពិសោធន៍របស់ពួកគេ នៅក្នុងថ្នាក់រៀនដោយរបៀបណា ?



*សូមអានផ្នែកទាំងនេះ ហើយធ្វើតាមការណែនាំ ។ សូមកត់ត្រាទុកនូវអ្វីដែលអ្នកកំពុងរៀនសូត្រនៅក្នុងទំព័រពិភាក្សា ។*

## *កំណត់*

នៅក្នុងវគ្គសិក្សាមូលដ្ឋានគ្រឹះ ឯកសាររៀបចំសម្រាប់ថ្នាក់មានគោលបំណងដើម្បីឲ្យអ្នក និងសិស្សរបស់អ្នកសិក្សាដើម្បីរៀបចំខ្លួនរៀនសូត្រ ។ ឯកសាររៀបចំមាននូវការអញ្ជើញដើម្បីលើកកម្ពស់ការរៀបចំខ្លួនរបស់សិស្ស និងគ្រូបង្រៀនតាមរយៈសំណួរ និងសកម្មភាពនានា ដែលមានបំណងជួយពង្រីកដល់ការរៀនសូត្រទាំងនៅក្នុង និងនៅក្រៅថ្នាក់រៀន ។ ការអញ្ជើញទាំងនេះនីមួយៗមានអមដោយរូបតំណាង ដើម្បីជួយអ្នកឲ្យមើលឃើញពីរបៀប និងពេលវេលាដែលត្រូវប្រើការអញ្ជើញទាំងនេះ ព្រមទាំងរបៀបដែលអ្នកអាចផ្អែកលើការអញ្ជើញទាំងនេះបាននៅក្នុងថ្នាក់រៀន ។

## *គំរូ*

នេះជាឧទាហរណ៍ពីរបីនៃការអញ្ជើញឲ្យរៀបចំខ្លួនទាំងនេះ ដែលអ្នកអាចរកឃើញនៅក្នុងកម្មវិធីសិក្សានេះ ៖

### សញ្ជឹងគិតនៅក្នុងការរៀបចំសម្រាប់ថ្នាក់រៀន

ឧទាហរណ៍ ៖ « តើបទពិសោធន៍អ្វីខ្លះដែលបានជួយអ្នកឲ្យដឹងថា ព្រះគម្ពីរមរមនគឺជាព្រះបន្ទូលរបស់ព្រះ ? »

### ការសិក្សានៅក្នុងការរៀបចំសម្រាប់ថ្នាក់រៀន

ឧទាហរណ៍ ៖ « ព្យាការីអាលម៉ាបានបង្រៀនប្រជាជនអំពីដង្វាយធួនរបស់ព្រះអង្គសង្គ្រោះ ។ សូមអាន អាលម៉ា ៧:១១-១៣ »។

### កត់ត្រាគំនិតរបស់អ្នក

ឧទាហរណ៍ ៖ « នៅក្នុងសៀវភៅកំណត់ហេតុរបស់អ្នក ឬនៅចន្លោះដែលផ្ដល់មក សូមសរសេរសេចក្ដីពិតពីរបីដែលអ្នកចាប់អារម្មណ៍ចេញពីវគ្គបទគម្ពីរ និងការបង្រៀននានានៅក្នុងផ្នែកនេះ ក៏ដូចជាគំនិត និងសំណួរផ្សេងៗទៀតដែលអ្នកមានផងដែរ ។ សូមមកកាន់ថ្នាក់រៀនដោយបានរៀបចំខ្លួនចែកចាយសេចក្ដីពិត ដែលអ្នកបានរកឃើញ និងការយល់ដឹងនានា ។ »

## ពិភាក្សាក្នុងការរៀបចំសម្រាប់ថ្នាក់

ឧទាហរណ៍ ៖ « ដោយមានជំនួយពីសមាជិកគ្រួសារ ឬមិត្តម្នាក់ សូមរកមើលការអនុវត្តនាពេលថ្មីៗនេះមួយចំនួនស្ដីពីគោលការណ៍ ដែលអ្នកបានរកឃើញពីខគម្ពីរទាំងនេះ ។ សូមមកកាន់ថ្នាក់រៀនដោយបានរៀបចំខ្លួនចែកចាយអ្វីដែលអ្នកបានរៀន » ។

## ធ្វើសកម្មភាពតាមអ្វីដែលអ្នកបានរៀន

ឧទាហរណ៍ ៖ « តើអ្នកនឹងធ្វើអ្វីខ្លះនៅប៉ុន្មានថ្ងៃ និងសប្ដាហ៍ខាងមុខនេះ ដើម្បីបម្រើមនុស្សដទៃដូចជាព្រះយេស៊ូវគ្រីស្ទ ? »

ឥឡូវ ដោយសារអ្នកបានឃើញពីរបៀបដែលកម្មវិធីសិក្សានេះ លើកកម្ពស់ដល់ការរៀបចំខ្លួនរបស់សិស្សតាមរយៈការអញ្ជើញហើយ សូមរៀនរកមើល និងប្រើប្រាស់ការអញ្ជើញទាំងនេះនៅក្នុងកម្មវិធីសិក្សា ។

## *អនុវត្ត*

សូមធ្វើតាមជំហានខាងក្រោមនេះដើម្បីរៀនរកមើល និងប្រើប្រាស់ការអញ្ជើញទាំងនេះ ដើម្បីលើកកម្ពស់ដល់ការរៀបចំខ្លួនរបស់សិស្ស ។

1. សូមចូលទៅមេរៀនមួយនៅក្នុងឯកសារគ្រូបង្រៀន ក្នុងវគ្គសិក្សាដែលអ្នកកំពុងបង្រៀន ឬនឹងបង្រៀន ហើយមើលការអញ្ជើញឲ្យរៀបចំខ្លួនដែលបានបង្ហាញឡើងទាំងឡាយ ។
2. សូមជ្រើសយកការអញ្ជើញមួយ ។
3. សូមពិចារណាថា តើការធ្វើសកម្មភាពនេះអាចមានសភាពយ៉ាងណានៅក្នុងការរៀបចំរបស់សិស្ស ។ សូមគិតអំពីឥទ្ធិពលដែលការប្រើប្រាស់ការអញ្ជើញឲ្យរៀបចំខ្លួននេះ អាចមានលើបទពិសោធន៍របស់សិស្សមុនពេល និងអំឡុងពេលបង្រៀន ។ សូមគិតអំពីរបៀបដែលអ្នកអាចអញ្ជើញសិស្សឲ្យរៀបចំខ្លួនសម្រាប់ម៉ោងរៀនលើកក្រោយ ដោយការជួយសិស្សឲ្យរកមើលការអញ្ជើញឲ្យរៀបចំខ្លួនទាំងនេះ ។
4. សូមរកមើលការអញ្ជើញឲ្យរៀបចំខ្លួនផ្សេងទៀត ហើយអនុវត្តវាសាឡើងវិញ ។

ការស្គាល់ និងការធ្វើឲ្យមានប្រសិទ្ធភាពក្នុងការប្រើប្រាស់ការអញ្ជើញឲ្យរៀបចំខ្លួន នឹងជួយអ្នកឲ្យផ្ដោតលើសិស្ស និងលើកកម្ពស់ការរៀបចំខ្លួនរបស់ពួកគេ ដើម្បីមានបទពិសោធន៍រៀនសូត្រកាន់តែជ្រាលជ្រៅមួយ ។

## *រួមបញ្ចូល*

នៅពេលអ្នកខិតខំលើកកម្ពស់ការរៀបចំខ្លួនរបស់សិស្សតាមរយៈការអញ្ជើញ សូមពិចារណាពីសំណួរដូចតទៅនេះ ៖

- នៅពេលអ្នកបង្រៀន តើអ្នកនឹងរួមបញ្ចូលអ្វីដែលអ្នកបានរៀនពីការអនុវត្តទាំងនេះដោយរបៀបណា ?
- តើអ្នកអាចធ្វើអ្វីខ្លះ ដើម្បីបន្តអនុវត្តជំនាញនេះ ដើម្បីអ្នកអាចធ្វើជាគ្រូបង្រៀនដែលកាន់តែប្រសើរម្នាក់ ?

## *ពិភាក្សា*

សូមកត់ត្រាទុកនូវអ្វីដែលអ្នកបានរៀនពីបទពិសោធន៍នេះ នៅក្នុងទំព័រពិភាក្សាខាងក្រោមនេះ ។ សូមប្រាកដថាបានអានអ្វីដែលអ្នកដទៃបានសរសេរ ដើម្បីមើលអ្វីដែលអ្នកដទៃកំពុងរៀនសូត្រ និងកំពុងធ្វើ ។

ឲ្យសិស្សចូលរួមដោយផ្អែកលើការរៀបចំខ្លួនរបស់ពួកគេ



## *ជំនាញ ៖ ឲ្យសិស្សចូលរួមដោយផ្អែកលើការរៀបចំខ្លួនរបស់ពួកគេ*

តើអ្នកនឹងឲ្យសិស្សរបស់អ្នកចូលរួមដោយរបៀបណា ដោយផ្អែកលើអ្វីដែលពួកគេបានសិក្សារៀនសូត្រ និងទទួលអារម្មណ៍ អំឡុងពេលរៀបចំខ្លួនរបស់ពួកគេដើម្បីរៀនសូត្រ ?



*សូមអានផ្នែកទាំងនេះ ហើយធ្វើតាមការណែនាំ ។ សូមកត់ត្រាទុកនូវអ្វីដែលអ្នកកំពុងរៀនសូត្រនៅក្នុងទំព័រពិភាក្សា ។*

## *កំណត់*

ពេញមួយវគ្គសិក្សាមូលដ្ឋានគ្រឹះនេះ កម្មវិធីសិក្សាអាចជួយអ្នកឲ្យទុកចិត្ត និងផ្តែកលើការរៀបចំខ្លួនរបស់សិស្សបាន ។ ឯកសារគ្រូបង្រៀនមាននូវការបំផុសគំនិតឲ្យចូលរួមជាច្រើន ដើម្បីអញ្ជើញសិស្សឲ្យ « ពិនិត្យមើល » « នឹកឃើញ » « ភ្ជាប់ » « ចែកចាយពីការរៀបចំខ្លួនរបស់ពួកគេ » ជាដើម ដើម្បីរំឭក និងលើកទឹកចិត្តអ្នកឲ្យប្រើប្រាស់ការយល់ដឹង និងការរៀបចំខ្លួនរបស់សិស្សដើម្បីដឹកនាំបទពិសោធន៍នៅក្នុងថ្នាក់រៀន ។

## *គំរូ*

នេះជាឧទាហរណ៍ពីរបីនៃការបំផុសគំនិតឲ្យចូលរួមទាំងនេះ ដែលអ្នកអាចរកឃើញនៅក្នុងកម្មវិធីសិក្សានេះ ៖

- « សូមឲ្យសិស្សប្រាប់ពីអ្វីដែលពួកគេចាំអំពីស្ថានភាពនេះ ចេញពីការរៀបចំខ្លួនដើម្បីរៀនសូត្ររបស់ពួកគេ » ។
- « សូមរំឭកសិស្សថា នៅក្នុងឯកសាររៀបចំ ពួកគេត្រូវបានអញ្ជើញឲ្យគូសចំណាំសេចក្តីពិត ដែលពួកគេបានចាប់អារម្មណ៍ ។ សូមផ្តល់ពេលខ្លះឲ្យសិស្សពិនិត្យមើលវគ្គបទគម្ពីរ និងការបង្រៀនរបស់ព្យាការី ដែលពួកគេបានគូសចំណាំទុកក្នុងផ្នែកនេះ ។ សូមឲ្យពួកគេចែកចាយអ្វីដែលពួកគេបានរៀនសូត្រជាមួយសិស្សក្នុងថ្នាក់ » ។
- « សូមអនុញ្ញាតឲ្យសិស្សពិភាក្សាគ្នាជាក្រុមតូចៗរយៈពេលពីរបីនាទី ពីរបៀបដែលពួកគេនឹងប្រើប្រាស់អ្វីដែលពួកគេបានរៀនសូត្រនៅក្នុងការរៀបចំខ្លួន ដើម្បីជួយដល់មិត្តភក្តិរបស់ពួកគេ » ។

ឥឡូវ ដោយសារអ្នកបានឃើញពីរបៀបដែលកម្មវិធីសិក្សានេះ ជួយអ្នកឲ្យផ្តែកលើការរៀបចំខ្លួនរបស់សិស្សហើយ សូមរៀនរកមើលការបំផុសគំនិតឲ្យចូលរួមទាំងនេះនៅក្នុងកម្មវិធីសិក្សានេះ ។

## *អនុវត្ត*

សូមធ្វើតាមជំហានខាងក្រោមនេះដើម្បីរៀនរកមើល និងប្រើប្រាស់ការបំផុសគំនិតឲ្យចូលរួមទាំងប៉ុន្មានបែបនេះ ដើម្បីផ្តែកលើការរៀបចំខ្លួនរបស់សិស្ស ។

1. សូមចូលទៅមេរៀនមួយនៅក្នុងឯកសារគ្រូបង្រៀន ក្នុងវគ្គសិក្សាដែលអ្នកកំពុងបង្រៀន ឬនឹងបង្រៀន ហើយមើលការបំផុសគំនិតឲ្យចូលរួមដែលបានបង្ហាញឡើងទាំងឡាយ ។
2. សូមជ្រើសយកការបំផុសគំនិតមួយ ។

3. សូមពិចារណាថា តើការធ្វើសកម្មភាពនេះអាចមានសភាពយ៉ាងណានៅក្នុងថ្នាក់រៀន ។ សូមគិតអំពីឥទ្ធិពលដែលការប្រើប្រាស់ការបំផុសគំនិតឲ្យចូលរួមនេះ អាចមានលើបទពិសោធន៍របស់សិស្ស ។
4. សូមកំណត់ការបំផុសគំនិតឲ្យចូលរួមផ្សេងទៀត ហើយធ្វើវាសាឡើងវិញ ។

ការស្គាល់ និងការធ្វើឲ្យមានប្រសិទ្ធភាពក្នុងការប្រើប្រាស់ការបំផុសគំនិតឲ្យចូលរួម នឹងជួយអ្នកឲ្យផ្ដោតលើសិស្ស និងឲ្យពួកគេចូលរួមក្នុងបទពិសោធន៍រៀនសូត្រដ៏ជ្រាលជ្រៅមួយ ។

## *រួមបញ្ចូល*

នៅពេលអ្នកខិតខំបង្កើនឲ្យមានការចូលរួមនៅក្នុងថ្នាក់រៀន ដោយផ្អែកលើការរៀបចំខ្លួនរបស់សិស្ស សូមពិចារណាពីសំណួរដូចតទៅនេះ ៖

- នៅពេលអ្នកបង្រៀន តើអ្នកនឹងរួមបញ្ចូលអ្វីដែលអ្នកបានរៀនពីការអនុវត្តទាំងនេះដោយរបៀបណា ?
- តើអ្នកអាចធ្វើអ្វីខ្លះ ដើម្បីបន្តអនុវត្តជំនាញនេះ ដើម្បីអ្នកអាចធ្វើជាគ្រូបង្រៀនដែលកាន់តែប្រសើរម្នាក់ ?

## *ពិភាក្សា*

សូមកត់ត្រាទុកនូវអ្វីដែលអ្នកបានរៀនពីបទពិសោធន៍នេះ នៅក្នុងទំព័រពិភាក្សាខាងក្រោមនេះ ។ សូមប្រាកដថាបានអានអ្វីដែលអ្នកដទៃបានសរសេរ ដើម្បីមើលអ្វីដែលអ្នកដទៃកំពុងរៀនសូត្រ និងកំពុងធ្វើ ។

សង្កត់ធ្ងន់លើការអនុវត្



## *ជំនាញ ៖ សង្កត់ធ្ងន់លើការអនុវត្ត*

តើអ្នកនឹងសង្កត់ធ្ងន់លើការអនុវត្តនៅក្នុងថ្នាក់របស់អ្នកយ៉ាងដូចម្ដេច ? តើអ្នកនឹងធ្វើអ្វីខ្លះដើម្បីលើកទឹកចិត្តសិស្សរបស់អ្នកឲ្យធ្វើសកម្មភាពតាមអ្វីដែលពួកគេបានរៀនសូត្រ ?



*សូមអានផ្នែកទាំងនេះ ហើយធ្វើតាមការណែនាំ ។ សូមកត់ត្រាទុកនូវអ្វីដែលអ្នកកំពុងរៀនសូត្រនៅក្នុងទំព័រពិភាក្សា ។*

## *កំណត់*

ការរៀបចំខ្លួនដ៏មានប្រសិទ្ធភាពរបស់សិស្ស និងគ្រូបង្រៀនពីមុនថ្នាក់រៀន អាចអនុញ្ញាតឲ្យមានពេលវេលាបន្ថែមទៀតនៅក្នុងថ្នាក់ ដើម្បីជួយសិស្សឲ្យកំណត់ពីរបៀបដើម្បីរស់នៅតាមសេចក្ដីពិត ដែលពួកគេបានរកឃើញនៅក្នុងមេរៀននេះ ។ ឯកសារគ្រូបង្រៀនត្រូវបានរៀបរៀងឡើងដើម្បីស្ថាបនាលើការរៀបចំខ្លួនរបស់សិស្ស ហើយជួយបង្កើនអំណាច និងសមត្ថភាពរបស់សិស្សដើម្បីធ្វើសកម្មភាពតាមរបៀបមួយ ដែលនឹងជួយពួកគេឲ្យប្រែក្លាយកាន់តែដូចជាព្រះវរបិតាសួគ៌ និងព្រះយេស៊ូវគ្រីស្ទ ។

## *គំរូ*

នេះជាឧទាហរណ៍ពីរបីនៃការពិភាក្សា និងការអញ្ជើញដោយផ្អែកលើការអនុវត្ត ដែលអ្នកអាចរកឃើញនៅក្នុងកម្មវិធីសិក្សាមូលដ្ឋានគ្រឹះនេះ ៖

- « សូមសួរសំណួរដូចតទៅនេះទៅកាន់សិស្ស ៖ តើអ្នក និងគ្រួសាររបស់អ្នកបានចូលរួមក្នុងកិច្ចការពង្សប្រវត្តិ និងការបម្រើក្នុងព្រះវិហារបរិសុទ្ធតាមរបៀបណាខ្លះ ? តើអ្នកទទួលបានពរជ័យអ្វីខ្លះមកពីការធ្វើដូច្នោះ ? អ្នកអាចអញ្ជើញសិស្សឲ្យគិតពីនរណាម្នាក់ ដែលពួកគេអាចសូមឲ្យជួយបង្រៀនពួកគេធ្វើកិច្ចការពង្សប្រវត្តិ ។ ប្រសិនបើសិស្សមួយចំនួនមានជំនាញចេះធ្វើកិច្ចការពង្សប្រវត្តិហើយ សូមអញ្ជើញពួកគេឲ្យបង្រៀនសិស្សផ្សេងទៀតនៅក្នុងថ្នាក់ » ។
- « សូមឲ្យសិស្សមានពេលខ្លះពិចារណា និងកត់ត្រាគំនិតរបស់ពួកគេអំពីសំណួរដូចតទៅនេះ ៖ តើខ្ញុំអាចកាន់តែសកម្មនៅក្នុងព្រះវិហារ និងជួយសម្រេចបានគោលបំណងរបស់សាសនាចក្រតាមរបៀបណា ? »
- « សូមបង្ហាញសំណួរដូចតទៅនេះ ៖ តើខ្ញុំនឹងធ្វើអ្វីខ្លះ ដើម្បីយាងព្រះចេស្ដានៃព្រះយេស៊ូវគ្រីស្ទមកក្នុងជីវិតរបស់ខ្ញុំឲ្យកាន់តែពេញលេញ ? សូមផ្ដល់ពេលឲ្យសិស្សសញ្ជឹងគិតពីសំណួរនេះប្រកបដោយការអធិស្ឋាន ហើយសរសេរចម្លើយក្នុងសៀវភៅកំណត់ហេតុ ឬសៀវភៅកត់ចំណាំរបស់ពួកគេ ។ កាលពួកគេកំពុងសញ្ជឹងគិត សូមពិចារណាបង្ហាញសម្ដីដកស្រង់មួយមកពីព្យាការីថ្ងៃចុងក្រោយម្នាក់ ដើម្បីលើកទឹកចិត្តពួកគេតាមរបៀបជាក់លាក់នានា ឲ្យយាងអញ្ជើញព្រះចេស្ដារបស់ព្រះអង្គសង្គ្រោះមកក្នុងជីវិតរបស់ពួកគេ » ។

ឥឡូវ ដោយសារអ្នកបានឃើញពីរបៀបដែលកម្មវិធីសិក្សានេះ ជួយអ្នកឲ្យសង្កត់ធ្ងន់លើការអនុវត្តរបស់សិស្សហើយ សូមរៀនរកមើលសកម្មភាពបង្រៀននៅក្នុងកម្មវិធីសិក្សា ។

## អនុវត្ត

សូមធ្វើតាមជំហានខាងក្រោមនេះដើម្បីរៀនរកមើល និងប្រើប្រាស់សកម្មភាពបង្រៀនទាំងឡាយ ដើម្បីសង្កត់ធ្ងន់លើការអនុវត្តរបស់សិស្ស ។

1. សូមចូលទៅមេរៀនមួយនៅក្នុងឯកសារគ្រូបង្រៀន ក្នុងវគ្គសិក្សាដែលអ្នកកំពុងបង្រៀន ឬនឹងបង្រៀន ហើយមើលសកម្មភាពបង្រៀនដែលបានបង្ហាញឡើងទាំងឡាយ ។
2. សូមជ្រើសយកសកម្មភាពបង្រៀនមួយ ហើយសូមអានដោយយកចិត្តទុកដាក់កាន់តែខ្លាំងលើសកម្មភាព និងសំណួរនានាដែលទាក់ទងនឹងការអនុវត្ត ។
3. សូមគិតអំពីឥទ្ធិពលដែលសកម្មភាពបង្រៀននេះ ឬសំណួរទាំងនេះ អាចមានលើបទពិសោធន៍របស់សិស្ស ។
4. សូមអនុវត្តវាសាឡើងវិញ តាមរយៈការជ្រើសយកមេរៀនមួយផ្សេងនៅក្នុងឯកសារគ្រូបង្រៀន ហើយរកមើលសកម្មភាពបង្រៀនដែលជួយឲ្យសង្កត់ធ្ងន់លើការអនុវត្ត ។

ការស្គាល់ និងការធ្វើឲ្យមានប្រសិទ្ធភាពក្នុងការប្រើប្រាស់ការពិភាក្សាដោយផ្អែកលើការអនុវត្តនឹងជួយអ្នកឲ្យផ្តោតលើសិស្ស ហើយអាចជួយពួកគេឲ្យប្រែក្លាយកាន់តែដូចជាព្រះវរបិតាសួគ៌ និងព្រះយេស៊ូវគ្រីស្ទ ។

## រួមបញ្ចូល

នៅពេលអ្នកខិតខំលើកទឹកចិត្តសិស្ស និងសង្កត់ធ្ងន់លើការអនុវត្ត សូមពិចារណាពីសំណួរដូចតទៅនេះ ។ សូមកត់ត្រាគំនិតរបស់អ្នកនៅក្នុងទំព័រពិភាក្សាខាងក្រោមនេះ ។

- នៅពេលអ្នកបង្រៀន តើអ្នកនឹងរួមបញ្ចូលអ្វីដែលអ្នកបានរៀនពីការអនុវត្តទាំងនេះដោយរបៀបណា ?
- តើអ្នកអាចធ្វើអ្វីខ្លះ ដើម្បីបន្តអនុវត្តជំនាញនេះ ដើម្បីអ្នកអាចធ្វើជាគ្រូបង្រៀនដែលកាន់តែប្រសើរម្នាក់ ?

## ពិភាក្សា

សូមកត់ត្រាទុកនូវអ្វីដែលអ្នកបានរៀនពីបទពិសោធន៍នេះ នៅក្នុងទំព័រពិភាក្សាខាងក្រោមនេះ ។ សូមប្រាកដថាបានអានអ្វីដែលអ្នកដទៃបានសរសេរ ដើម្បីមើលអ្វីដែលអ្នកដទៃកំពុងរៀនសូត្រ និងកំពុងធ្វើ ។

# *សេចក្ដីសង្ខេប*

សូមអរគុណចំពោះការព្រមទទួលយកឱកាស ដើម្បីជួយសិស្សរបស់អ្នកឲ្យមានការផ្លាស់ប្រែចិត្តជឿកាន់តែជ្រាលជ្រៅទៅលើព្រះយេស៊ូវគ្រីស្ទ និងដំណឹងល្អរបស់ទ្រង់ដែលបានស្ដារឡើងវិញ ។

## *សូមចងចាំ ៖*

- ព្រះអម្ចាស់នឹងណែនាំអ្នក នៅពេលអ្នកព្យាយាមជួយសិស្សរបស់អ្នកឲ្យមករកព្រះគ្រីស្ទ និងកាន់តែប្រែក្លាយដូចជាទ្រង់ ។
- អ្នកសម្របសម្រួល ឬនាយកថ្នាក់វិទ្យាស្ថានរបស់អ្នកអាចជួយអ្នកឆ្លើយនឹងសំណួរ ឬកង្វល់ណាមួយដែលអ្នកមានបាន ។
- ជំនាញដែលត្រូវបានកំណត់ ដាក់ជាគំរូ និងអនុវត្តនៅក្នុងការបំពាក់បំប៉ននេះ អាចជួយអ្នកឲ្យកាន់តែមានប្រសិទ្ធភាពក្នុងការប្រើប្រាស់កម្មវិធីសិក្សាដើម្បីផ្ដល់ពរជ័យដល់សិស្សរបស់អ្នក ។ ជំនាញទាំងនេះអាចជួយអ្នកឲ្យផ្ដល់បទពិសោធន៍ដែលស្អាងឡើង និងប្រែចិត្តជឿដល់សិស្សទាំងឡាយ កាលអ្នកព្យាយាមជួយពួកគេឲ្យរៀបចំខ្លួន ចូលរួម និងធ្វើសកម្មភាព ដើម្បីជួយពួកគេឲ្យក្លាយដូចជាព្រះអង្គសង្គ្រោះព្រះយេស៊ូវគ្រីស្ទ ។

